**SPRING PARKS PRIMARY SCHOOL**
*Learning and Growing - Safety - Together*

West Campus - Administration
24 Erica Street, Springvale 3171 ☎ 9546 6402

Valley Campus
27-39 Clarke Road, Springvale South 3172 ☎ 9547 3222
✉ spring.parks.ps@education.vic.gov.au springparksps.vic.edu.au





## កិច្ចសម្ភាសន៍រវាងមាតាបិតានិងគ្រូ:

គ្រួសារទាំងឡាយនឹងទទួលប័ណ្ណជូនដំណឹងអំពីកិច្ចសម្ភាសន៍ដែលនឹងប្រព្រឹត្តឡើងនៅថ្ងៃពុធទី១២ ខែ កក្កដា (ត្រីមាសទី៣) នៅពេលបន្តិចទៀតនេះ: ព្រោះ:មានគ្រូមួយចំនួនធំបានទៅវិស្សមកាលមួយរយ:ពេលនៅត្រីមាសនេះ:ក្នុងក្របខណ្ឌបំរើការងារយូរ ឆ្នាំ។ មានតែគ្រូម្នាក់គត់ដែលនឹងធ្វើសម្ភាសន៍ក្នុងត្រីមាសនេះ:គឺ Mrs Otenstein ហើយថ្ងៃសម្ភាសន៍របស់អ្នកគ្រូគឺថ្ងៃអង្គារ ទី២០ ខែមិថុនា។សូមយកប័ណ្ណជ្រើសរើសពេលវេលមកសាលាវិញឲ្យបានរួសរាន់,ដើម្បីឲ្យការជ្រើសរើសរបស់លោកអ្នកអាចបំពេញដូចសេចក្ដីរំពឹង។យើងខ្ញុំចង់ឃើញគ្រួសារមកជួបគ្រូរបស់កុមារឲ្យបានច្រើន។របាយការណ៏នៃត្រីមាសទី១នឹងអាចមើលតាមរយ: Parent Portal Sentral នៅថ្ងៃទី២១ ខែមិថុនា,ដូច្នេ:បើមាតាបិតាមិនទាន់ចូលច្រកពត៍មាននេះ:ទេ, សូមចូលដើម្បីមានពេលមើលរបាយការណ៏មុនពេលមកជួបសម្ភាសន៍ជាមួយគ្រូរបស់កុមារ។ គ្រួសារដែលមានកូនស្ថិតក្នុងកម្មវិធីទទួលកគាំទ្រជាពិសេសPSD នឹងបានស្ដាប់អំពីលទ្ធផលរបស់កុមារក្នុងត្រីមាសនេះ:មានរយ:ពេលយូរជាង។

## កំណត់ប្រចាំថ្ងៃ:15/5/2023

១៥/៥: វ៉ែនតាសំរាប់កុមារ:សាខាខាងលិច:ថ្នាក់មូលដ្ឋាន–ទី៣
១៦/៥: វ៉ែនតាសំរាប់កុមារ:សាខាវ៉ាល្លី: ថ្នាក់មូលដ្ឋាន–ទី៣
ពេលជួបនឹងឆ្កែដ៏ស្និទ្ធស្និទ្ធស្នាល
១៨/៥: ថ្ងៃបើកទ្វារឲ្យមាតាបិតាទស្សនាថ្នាក់រៀនសំរាប់សប្ដាហ៏អប់រំ:ម៉ោង១២–២
១៩/៥: គោរពទង់ជាតិ:ចាត់ចែងដោយថ្នាក់ 1/2M & 3/4A
កិច្ចប្រជុំនៃក្រុមប្រឹក្សាសាលា:ម៉ោង៦:០០ល្ងាច
២៣/៥: ពេលជួបនឹងឆ្កែដ៏ស្និទ្ធស្និទ្ធស្នាល
២៦/៥: គោរពទង់ជាតិ:ចាត់ចែងដោយថ្នាក់ 3/4B & 3/4M
ថ្ងៃគំរោងកម្មវិធីសិក្សា:សិស្សសំរាកនៅថ្ងៃនេះ:




## ពេលរៀនអំពីសុវត្ថិភាពនៃការប្រើអ៊ិនធើណែត:

បុគ្គលិកនិងកុមារមានការរីករាយជាពន្លឺកដែលបានចូលរួមក្នុងពេលរៀនមួយប្រកបទៅដោយភាពជាក់ស្ដែងនិងពោរពេញទៅដោយចំណេ:ដឹងនាថ្ងៃ ទី៣ ខែ ឧសភា។ យើងខ្ញុំបានរៀនពីជំនាញនិងយុទ្ធសាស្ត្រដើម្បីរក្សាខ្លួននិងសិស្សានុសិស្សឲ្យបានសុខនៅពេលប្រើអ៊ិធើណែត។ នៅមានពេលសិក្សាចំនួនពីរលើកទៀតសំរាប់មាតាបិតា,សូមចូលរួមបើត្រូវការ។យើងខ្ញុំនឹងបន្តទំនាក់ទំនងនឹងក្រុម Cyber Safety (សុវត្ថិភាព អ៊ិនធើណែត) ព្រោះ:នេះ:ជាវិស័យមួយមានការផ្លាស់ប្ដូរយ៉ាងលឿន,ហើយយើងត្រូវតាមឲ្យបានទាន់សម័យចំពោះ:ការរីកចំរើនដ៏ថ្មីនេះ:។

## វិស្សមកាលនៃគ្រូមានសេវាកម្មយូរឆ្នាំ:

មានគ្រូមួយចំនួនធំបានទៅវិស្សមកាលនៅត្រីមាសនេះ:ដោយបានបម្រើការងារយូរឆ្នាំ។តែជាកុសលព្រោះ:យើងមានគ្រូដ៏មានបទពិសោធន៍ដ៏បរិបូរណ៍មកជំនួស។Mrs McClaren នឹងសំរាកចាប់ពីថ្ងៃទី១៥/៥រហូតដល់ចុងត្រីមាសនេះ:,តែMrs Farmer នឹងមកបង្រៀនជំនួសពេញពេលនៅពេលអវត្តមានរបស់អ្នកគ្រូ។Mrs Ary ចាប់ផ្ដើមសំរាកនៅថ្ងៃទី១២/៥, ហើយយើងខ្ញុំមានគ្រូថ្នាក់មូលដ្ឋានដ៏មានការពិសោធន៏មកជំនួស។នេះ:ជាការល្អមួយ។ ធម្មតាក្រុមហ៊ុនផ្គត់ផ្គង់គ្រូបង្រៀនបណ្ដោ:អាសន្នមិនអាចធនាផ្ដល់ឲ្យគ្រូដដែលៗរៀងរាល់អាទិត្យនោ:ទេ,ប៉ុន្តែMrs Hemer នឹងបង្រៀនជំនួសពេញពេល។Mrs Wirrick នឹងសំរាកចាប់ពីថ្ងៃទី១៣/៦ដល់១៦/៦,Mrs Hancock & Mrs Farmer នឹងសំរាកនៅសប្ដាហ៏ចុងក្រោយនៃត្រីមាសនេះ:។សូមឲ្យពីរសប្ដាហ៏ទៅមុខនេះ:ប្រកបដោយក្ដីសុខនិងសប្បាយ។

Julie Fisher: នាយកសាលា

## សប្តាហ៏អប់រំ

សប្តាហ៏នេះជាសប្តាហ៏អប់រំ,សាលានឹងអបអរសាទរព្រឹត្តិការណ៏នេះ នៅថ្ងៃព្រហស្បត៏ទី១៨/៥ដោយទុកពេលពីម៉ោង១២:០០-ម៉ោង ២:០០ឲ្យមាតាបិតានិងគ្រួសារមកមើលថ្នាក់កំពុងរៀន។ ស្វាគមន៏មាតាបិតាមកមើលក្នុងថ្នាក់រៀនក្នុងរយៈពេលពីរម៉ោងនេះថាតើមានអ្វីកើតឡើងក្នុងថ្នាក់។លោកអ្នកមិនចាំបាច់រាយការណ៏ប្រាប់កា រិយាល័យឡើយ,សូមចូលតម្រង់ក្នុងថ្នាក់រៀនតែម្តង។

## ការលុបចោលប្រធានបទរៀនសូត្រជូនមាតាបិតាតាមអ៊ិនធើណែត

សូមអរគុណដល់មាតាបិតា/អាណាព្យបាលដែលបានឆ្លើយតបនឹងកម្រងសំណួររបស់យើងទាក់ទងទៅនឹងការជូនពេលរៀនខ្លីៗសំរាប់គ្រួសារលើប្រធានបទផ្សេងៗ។ជាការសោកស្តាយព្រោះមានតែ ១០គ្រួសារប៉ុណ្ណោះបានបង្ហាញចំណាប់អារម្មណ៏ក្នុងការចូលរួម។យោងទៅលើចំនួនដ៏ទាបនេះ,យើងខ្ញុំមិនអាចចាត់ចែងពេលរៀនសូត្រនេះបាននៅពេលនេះ។ខាងក្រោមនេះជាគេហទំព័រមួយចំនួនដែលយើងខ្ញុំសង្ឃឹមថាអាចផ្តល់ពត៏មាននិងជំនួយដ៏ច្រើនដល់គ្រួសារជាជំនួស។

ចំពោះជំនួយខាងផ្លូវច្បាប់ដោយឥតគិតថ្លៃ(មានរួមទាំងការផ្តល់យោបល់ដល់អ្នកកាន់ទិដ្ឋការបណ្តោះអាសន្ន): Temporary Visa

https://www.smls.com.au/#section_1

ចំពោះជំនួយខាងហិរញ្ញវត្ថុ ;Free Financial Counselling :

https://ndh.org.au/

ពេលអង្គុយនៅមុខអេក្រង់និងទល់មុខអេក្រង់ដោយសុវត្ថិភាព:

Screen Time and Screen Safety:-
https://www.esafety.gov.au/

គាំទ្រសុខភាពស្មារតីកុមារ: Supporting your Child’s Mental Health:-

https://www.thinkmentalhealthwa.com.au/supporting-others-mental-health/for-parents/

របៀបចិញ្ចឹមកូនដ៏វិជ្ជមាននិងទំនាក់ទំនងនឹងកុមារឲ្យបានល្អជាង:

Positive Parenting & Improving  Communication with your Child:-  https://services.dffh.vic.gov.au/parentline, https://raisingchildren.net.au/

## តូបលលក់ឥវ៉ាន់សំរាប់ថ្ងៃមាតា

ខ្ញុំសង្ឃឹមថាគ្រួសារបានរីករាយនឹងថ្ងៃមាតាពីម្សិលមិញ,ហើយពេញចិត្តនឹងរបស់ដែលកុមារបានទិញឲ្យម្តាយរបស់ខ្លួនពីតូបលក់ឥវ៉ាន់សលា។កុមាររីករាយហើយចូលចិត្តចំណាយប្រាក់ដើម្បីទិញឥវ៉ាន់ឲ្យម្តាយ,យាយ,មីងឬមិត្តភេទស្រីរបស់ខ្លួន។តូបលក់ឥវ៉ាន់នៅសាខាទាំងពីរបានចំណេញប្រាក់សារុបចំនួន $1.108,50 ក្រោយពីបានដកប្រាក់ចំណាយចេញ។សាលានឹងយកប្រាក់នេះទៅទិញប្រដាប់ប្រដារផ្សេងៗឲ្យសាលានៅថ្ងៃក្រោយ។សូមអរគុណដល់ Robyn & Di ដែលបានរៀបចំកាដូ,ការតាំងវត្ថុសំរាប់លក់ហើយនៅត្រៀមខ្លួនជា និចនៅរាល់ពេលដើម្បីសង្កេតការលក់ដូរ។

## អំណោយពី Zart Art

សូមអរគុណចំពោះអំណោយជាប្រអប់និងសម្ភារៈសិល្បៈចម្រុះពណ៌ទាំងនេះពី Zart Art ។សម្ភារៈទាំងនេះនឹងធ្វើឲ្យបន្ទប់រៀនសិល្បៈរឹងរឹតតែមានពណ៌ស្អាតថែមឡើង។





# តូបលក់ឥវ៉ាន់សំរាប់ថ្ងៃមាតា





















# កូនឆ្កែដ៏ស្និទ្ធស្នាល























## STARS OF THE WEEK

### WEST CAMPUS

| Grade | Week 2 | Week 3 |
|---|---|---|
| FA | Tabitha –Vincent | Varadan– Omida |
| 1/2 A | | |
| 1/2 B | Mila | Norah |
| 3/4 A | Emily | Henry |
| 3/4 B | Ailin– Aiden | Kenny |
| 5/6 A | William-Jemma | |
| 5/6 B | Eren | Himson |
| Art | | |
| PE | Ravneet 3/4B | Morokot |
| Spanish | Taryn 1/2B | Tabitha |

### VALLEY CAMPUS

| Grade | Week 2 | Week 3 |
|---|---|---|
| FK | Sophia | Peggy |
| 1/2 L | Lewis | Cassandra |
| 1/2 M | Amira | William |
| 3/4 L | Kylie | Ayesha |
| 3/4 M | Christina | Angela |
| 5/6 L | Mariah | |
| 5/6 M | Mia | |
| Art | Cataleya– Chloe | Gohan |
| PE | Kieran-Sophia | Adam |
| Spanish | Xavier– Ellie | Krystal |